**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មូលនិធិជនពិការ**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ០០៧...... មជព/គល

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
ចូល
លេខ......0518......
ថ្ងៃទី 31.01.19 ម៉ោង 11:00
បញ្ជូន......

ការិយាល័យរដ្ឋបាល ក្រ.សហវ
មកដល់ថ្ងៃទី 29.01.19 ម៉ោង 15.30
លេខ: 239 C ...... សហវ
អ្នកទទួល:...... ហត្ថលេខា......
អ្នកប្រគល់:...... ហត្ថលេខា......
បញ្ជូនទៅ:......

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃលើការផ្គត់ផ្គង់ ប្រេងឥន្ធនៈ ជូនមូលនិធិជនពិការ សម្រាប់ឆ្នាំ២០១៩

មូលនិធិជនពិការ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា មូលនិធិជនពិការ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ ប្រេងឥន្ធនៈ ឆ្នាំ២០១៩។

មូលនិធិជនពិការ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃមូលនិធិជនពិការ ដែលមានអាសយដ្ឋានផ្លូវលេខ៦អា សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ចាប់ពីថ្ងៃពុធ ១០រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ វេលារាល់ម៉ោងធ្វើការ។

ឯកសារដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុត ត្រឹមថ្ងៃសុក្រ ១០រោច ខែមាឃ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៩:០០ នាទីព្រឹក។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅមូលនិធិជនពិការ វេលាម៉ោង៩:០០ នាទីព្រឹក ថ្ងៃសុក្រ ១០រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ អង្គារ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួរ រតនៈ**

**ចម្លងជូន**
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)*
*-អង្គភាពប្រឆាំងអំពើពុករលួយ*
*-ឯកសារ-កាលប្បវត្តិ*

សូមទាក់ទង
ទូរស័ព្ទលេខ: ០២៣ ៩៨២ ៣០៦

មូលនិធិជនពិការ ផ្លូវជាតិលេខ ៦A ភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៩៨២ ៣០៦
Persons with Disabilities Foundation, Road 6A, Phum Kien Khleang, Sangkat Chroy Changva, Khan Chroy Changva, Phnom Penh, Cambodia. Phone/Fax: (855) 23 982 306